# ការទទួលខុសត្រូវលើផលិតផលក្នុងក្រមរដ្ឋប្បវេណីកម្ពុជា

## ក. សេចក្តីផ្តើម

ក្នុងជំពូកស្តីពី អំពើអនីត្យានុកូល មានបទប្បញ្ញត្តិ ស្តីពីការទទួលខុសត្រូវលើផលិតផល។ បទប្បញ្ញត្តិ មិនបានចែងលម្អិតទេ ហើយការស្រាវជ្រាវ ផ្តោតលើប្រធានបទនេះ ក៏នៅមានកម្រិត គួបផ្សំនឹងមានសំណួរមួយចំនួនពាក់ព័ន្ធនឹងខ្លឹមសារ អ្នកនិពន្ធបានសម្រេច យកមាត្រាពាក់ព័ន្ធមកពិនិត្យ ព្យាយាមបង្ហាញខ្លឹមសារ ដោយយោងដល់បទអធិប្បាយរបស់អ្នកជំនាញពាក់ព័ន្ធនឹងមាត្រានេះផងដែរ។

វាគ្រាន់តែជាការសិក្សាបឋម ផ្តោតលើទ្រឹស្តី ដោយសារ មិនមានសាលក្រមឬ សាលដីកា ដែលអ្នកនិពន្ធ អាចយកមកវិភាគស៊ីជម្រៅបានទេ។ ទោះបីជាយ៉ាងនេះ មានការរំពឹងថា អត្ថបទខ្លីនេះ នឹងជាមូលដ្ឋានសម្រាប់ការសិក្សាបន្តទៀតរបស់អ្នកស្រាវជ្រាវថ្មីៗ។

## ខ. ការទទួលខុសត្រូវលើផលិតផល

មាត្រា ៧៤១.- ការទទួលខុសត្រូវចំពោះផលិតផលរបស់អ្នកផលិតវត្ថុ

*១- ក្នុងករណីដែលមានវិការៈ នាំឱ្យមានគ្រោះថ្នាក់មិនសមហេតុផល ក្នុងចលនវត្ថុដែលត្រូវបានផលិត ហើយបានបណ្តាលឱ្យមានការខូចខាតដល់អ្នកដទៃដោយវិការៈនោះ ផលិតករនៃចលនវត្ថុនោះត្រូវទទួលខុសត្រូវក្នុងការសងនូវការខូចខាតនោះ។ ប៉ុន្តែបញ្ញត្តិនេះមិនត្រូវអនុវត្តឡើយចំពោះករណីដែលមិនអាចប្រមាណនូវវិការៈនោះ តាមកម្រិតវិទ្យាសាស្ត្រនៃបច្ចេកទេសដែលមាននៅសម័យដែលផលិតនោះ។*

*២- អ្នកដែលផលិតចលនវត្ថុដែលផ្សំដោយគ្រឿង ឬវត្ថុធាតុដើមដែលមានវិការៈត្រូវទទួលខុសត្រូវក្នុងការសងនូវការខូច ខាត ក្នុងនាមជាផលិតករផងដែរ។ ៣- ក្នុងខ្លឹមសារនៃមាត្រា នេះចំពោះចលនវត្ថុដែលនាំចូល អ្នកនាំចូលត្រូវចាត់ទុកថាជាផលិតករ។ ៤- ក្នុងខ្លឹមសារនៃមាត្រា នេះបុគ្គលដែលបានដាក់សញ្ញាណនៃនាមករណ៍របស់ខ្លួនជាផលិតករ ឬអ្នកលក់ នៅលើវត្ថុត្រូវ ចាត់ទុកថាជាផលិតករនៃចលនវត្ថុនោះ។*

ជាដំបូងយើងត្រូវដឹងថា តើផលិតផលជាអ្វី។ ក្នុងក្រមរដ្ឋប្បវេណីទាំងមូល មិនមានចែងផ្តល់ន័យនៃពាក្យ “ផលិតផល”ទេ។ ទោះបីជាយ៉ាងនេះក្តី បើតាមអត្ថបទអធិប្បាយ ផលិតផល សំដៅលើវត្ថុដែលត្រូវបានផលិត។ នេះវាមានន័យត្រូវបានកែឆ្នៃ។ ត្រីដែល គេស្ងួច បានមិនមែនជាផលិតផលទេ។

គេមិនច្បាស់ថា តើវត្ថុធាតុដើម ត្រូវបានចាត់ទុកជាផលិតផលដែរឬទេ ទោះបីកថាខ័ណ្ឌទី២ នៃមាត្រា ៧៥១ ចែងឲ្យអ្នកផលិតវត្ថុធាតុដើមទទួលខុសត្រូវផងដែរ ករណីមានវិការៈ។ វាមិនរាប់បញ្ចូលនូវអចលនៈទ្រព្យ ដូចជា ផ្ទះទេ។ ផលិតផល អាចជាផលិតផលសម្រេច ឬគ្រឿងផ្សំ។

តាមខ្លឹមសារ អ្នកទទួលខុសត្រូវ គឺ ផលិតករ។ បន្ថែមពីលើនេះ អ្នកផលិតវត្ថុធាតុដើម ឬ គ្រឿងផ្សំ ក៏ត្រូវទទួលខុសត្រូវផងដែរ។ អ្នកនាំចូលចលនវត្ថុ ឬបុគ្គលដាក់នាមខ្លួនលើផលិតផល ថាជាផលិតករ ឬអ្នកលក់ ត្រូវចាត់ជាផលិតករ ដែលជាប្រយោល ក៏ត្រូវទទួលខុសត្រូវផងដែរ។

ការទទួលខុសត្រូវលើផលិតផលរបស់ផលិតករ ជាការទទួលខុសត្រូវតឹងរឹង (strict liability)។ ក្នុងន័យថា វានឹងមានការទទួលខុសត្រូវទោះបី គ្មានចេតនា ឬគ្មានការធ្វេសប្រហែសក្តី។ អ្វីដែលសំខាន់គឺ ផលិតផលនោះ មានវិការៈ ដែលទំនងមិនមែនជាវិការៈសាមញ្ញទេ ដោយសារថា វាទាមទារឲ្យមាន "គ្រោះថ្នាក់មិនសមស្រប"។ ទោះបីជាមានវិការៈក្តី ក៏ប៉ុន្តែប្រសិនបើមិនមានការខូចខាតដល់អ្នកដទៃ ផលិតករ ជាទូទៅ ក៏មិនទទួលខុសត្រូវដែរ។

អ្វីជាវិការៈ? មាត្រា ៧៥១ មិនបានចែងន័យទេ ក៏ប៉ុន្តែក្នុងបទអធិប្បាយ វិការៈតាមច្បាប់ជប៉ុន មានន័យថា៖ *សំដៅទៅលើកង្វះនូវសុវត្ថិភាពដែលចាំបាច់ត្រូវមានជាធម្មតាសម្រាប់ផលិតផលដែលបានផលិតឡើង ដោយគិតពិចារណានូវលក្ខណៈពិសេសនៃផលិតផលនោះ វិធីប្រើផលិតផលនោះដែលអាចត្រូវបានព្យាករបាន ពេលវេលាដែលអ្នកផលិតវត្ថុនោះជាអាទិ៍ បានប្រគល់ផលិតផលនោះ និងស្ថានភាពផ្សេងៗដែលពាក់ព័ន្ធនឹងផលិតផលនោះ*[1]។

ខ្លឹមសារនេះស្រដៀងគ្នានឹងន័យនៃវិការៈ កំណត់ដោយយុត្តាធិការរបស់រដ្ឋដទៃ ដែលផ្តោតសំខាន់លើសុវត្ថិភាពនាពេលប្រើប្រាស់ ដែលគេរំពឹងពីវត្ថុនោះ។ ក្នុងន័យនេះ ផលិតផល មានវិការៈ អាចខុសពីផលិតផលគ្មានគុណភាព។ រណា ត្រូវបានប្រើអារឈើឲ្យបានជោគជ័យ តែបានផ្លាត់មុតដាច់ម្រាមដៃ ក៏ព្រោះវាមានវិការៈ។

ក្នុងទំនាក់ទំនងរវាងអ្នកលក់ក្នុងកិច្ចសន្យាលក់ ពាក្យ"វិការៈ" ក៏ត្រូវបានប្រើ ដែលអ្នកនិពន្ធ គិតថា អត្ថន័យនៃវិការៈនោះ ក៏អាចជួយបំភ្លឺផងដែរ។ វិការៈ ក្នុងកិច្ចសន្យា សំដៅលើ ផលិតផលមិនស្របចំនួន ផ្សេងពីគម្រូដែលអ្នកលក់បានបង្ហាញ មិនសមស្របនឹងវិធីប្រើ។[2] ប្រសិនបើក្នុងវិសាលភាពន័យដូចនេះ

---

[1] Ministry of Justice, Note on Each Article of Civil Code, Book Five, 2010, p. 189.

[2] មាត្រា ៥៣៩៖ *លើកលែងតែគូភាគីបានកំណត់ផ្សេង វត្ថុដែលបានប្រគល់ឱ្យអ្នកទិញមានលក្ខណៈណាមួយដូចខាងក្រោមនេះ ត្រូវបានចាត់ទុកថាមានវិការៈ៖ ក- វត្ថុនោះមានភាពមិនស្របនឹងចំនួន គុណភាព និងលក្ខណៈដែលបានកំណត់ក្នុងកិច្ចសន្យា។ ខ- វត្ថុនោះមានភាពផ្សេងពីគំរូដែលអ្នកលក់ បានបង្ហាញឱ្យអ្នកទិញមើល ចំពោះចំនួន គុណភាព និងលក្ខណៈ។ គ- វត្ថុនោះមិនស្របនឹងវិធីប្រើ ដែលអ្នកលក់ត្រូវបានបង្ហាញ ដោយជាក់លាក់ ឬដោយតណ្ហីភាពនៅពេលធ្វើកិច្ចសន្យា។ ឃ- វត្ថុនោះមិនស្របនឹងវិធីប្រើធម្មតានៃវត្ថុប្រភេទដូចគ្នា។ ង- វត្ថុនោះមិនត្រូវបានខ្ចប់តាមវិធីធម្មតានៃការខ្ចប់វត្ថុប្រភេទដូចគ្នា ឬតាមវិធីសមរម្យ*

វិការៈក្តោបក្នុងដំណាក់កាល ដាក់លក់ និងធ្វើបទបង្ហាញ មិនក្តោបដំណាក់កាលរចនា និងផលិតទេ ដែលនេះខុសពីច្បាប់ ឬការអនុវត្តរបស់យុត្តាធិការដទៃទៀត។[3]

មាត្រា ៧៥១ ចែងករណីលើកលែងជាក់លាក់ ក្នុងករណីមួយ ដែលនាំឲ្យអ្នកផលិត រួចផុតពីការទទួលខុសត្រូវ។ វត្ថុមួយ ត្រូវបានផលិត ៥ឆ្នាំមុន ដែលក្នុងអំឡុងពេលនោះ ផ្អែកតាមបច្ចេកវិជ្ជានាពេលនោះ អ្នកផលិតមិនអាចព្យាករណ៍អំពីវិការៈ ពេលនេះ (៥ឆ្នាំក្រោយ) បានទេ។ ដូចនេះ ប្រាំឆ្នាំក្រោយមក ធៀបជាមួយនឹងទំនិញដូចគ្នា ទំនិញ ៥ឆ្នាំ មុនមានវិការៈ។ ក្នុងន័យនេះ និយាយជាសាមញ្ញ គេមិនអាចបន្ទោសផលិតករបានទេ ហើយក៏មិនអាចយកអះអាងថា មានវិការៈ នាំឲ្យផលិតករទទួលខុសត្រូវទេ។ នេះដោយសារថា គេមិនអាចព្យាករណ៍បាន ហើយប្រសិនបើដាក់ឲ្យផលិតករ ទទួលខុសត្រូវ វានឹងបង្អាក់ និងមានការញញើតនូវការផលិតអ្វីដែលថ្មី។ ក្នុងខ្លឹមសារច្បាប់ គំហើញបច្ចេកវិជ្ជាថ្មី នឹងមិនត្រូវអនុវត្តថយក្រោយទេ។

មានបញ្ហាមួយចំនួនៈ កថាខ័ណ្ឌខាងលើបង្ហាញនូវមូលដ្ឋាន នាំឲ្យផលិតករមិនទទួលខុសត្រូវ។ ក្រមរដ្ឋប្បវេណី ដែលចែងពាក់ព័ន្ធនឹងអំពើអនីត្យានុកូល មានចែងនូវមូលហេតុដោះសារជាច្រើន។ អ្វីជាសំណួរថាតើមូលដ្ឋានទាំងនោះ អាចត្រូវបានអ្នកផលិត យកមកសំអាងដែរឬទេ ដើម្បីឲ្យរួចផុតពីការទទួលខុសត្រូវលើផលិតផលរបស់ខ្លួន។ ក្រៅពីនេះ នៅមានសំណួរ ឬបញ្ហាចោទផ្លូវច្បាប់មួយចំនួនទៀត ដែលទាមទារការបកស្រាយ ដែលអ្នកនិពន្ធនឹងរៀបរាប់តាមលំដាប់ដូចខាងក្រោម។

**ក. មូលដ្ឋាននៃការដោះសារ៖** ក្រមបានចែងនូវប្រភេទនៃការដោះសារជាច្រើន៖ ការពារធម្មានុរូប និងស្ថានភាពចាំបាច់ [4] ការទទួលយកនូវហានីយភ័យ[5] អសមត្ថភាពក្នុងការទទួលខុសត្រូវ (ករណីអនីតិជន)[6] ការបំពេញករណីកិច្ចត្រួតពិនិត្យជាប្រក្រតី[7] ការត្រួតពិនិត្យដោយត្រឹមត្រូវ[8] ប្រធានសក្តិ អំពើជនរងគ្រោះ ឬតតិយជន[9] គ្រប់គ្រងដោយត្រឹមត្រូវ[10]។ មូលដ្ឋានទាំងនេះ មួយចំនួន ដូចជា ការពារធម្មានុរូប

---

*ដើម្បីការពារវត្ថុនោះ។*

[3] Piotr Machnilowski ed., European Product Liability, An Analysis of the State of the Art in the Era of New Technologies (EU Product Liability) 2016, p. 126។

[4] ក្រមរដ្ឋប្បវេណី មាត្រា ៧៥៥។

[5] ក្រមរដ្ឋប្បវេណី មាត្រា ៧៥៦។

[6] ក្រមរដ្ឋប្បវេណី មាត្រា ៧៤៥។

[7] ក្រមរដ្ឋប្បវេណី មាត្រា ៧៤៦ (ការទទួលខុសត្រូវរបស់អ្នកមានករណីកិច្ចត្រួតពិនិត្យ)។

[8] ក្រមរដ្ឋប្បវេណី មាត្រា៧៤៧ (ការទទួលខុសត្រូវរបស់និយោជក)។

[9] ក្រមរដ្ឋប្បវេណី មាត្រា ៥៥២ (ការទទួលខុសត្រូវចំពោះវត្ថុគ្រោះថ្នាក់)។

[10] ក្រមរដ្ឋប្បវេណី មាត្រា ៧៥៣ (ការទទួលខុសត្រូវចំពោះសំណង់ដែលជាប់នឹងដី)។

ត្រូវបានចែងជាទូទៅ ក៏ប៉ុន្តែ ការត្រួតពិនិត្យដោយត្រឹមត្រូវ ជាមូលដ្ឋានជាក់លាក់ អនុវត្តចំពោះតែការទទួលខុសត្រូវរបស់និយោជកតែប៉ុណ្ណោះ។ អ្នកនិពន្ធយល់ ថាប្រសិនបើវាជាមូលដ្ឋាន ដែលអាចអនុវត្តទូទៅ ដូចជា ការទទួលយកហានីយភ័យដោយជនរងគ្រោះ ក៏អាចជាការដោះសារ ត្រូវបានលើកឡើងផងដែរ ដោយអ្នកផលិត។ មាត្រា ៧៥១ មិនហាមឃាត់នោះទេ ហើយបទអធិប្បាយនៃមាត្រានេះ ក៏មិនបានអះអាងថា មូលដ្ឋានដោះសារ មានតែមួយគត់ ដូចដែលបានចែងក្នុងមាត្រា ៧៥១ ស្រាប់។ បន្ថែមពីលើនេះ វាក៏ អាចត្រូវបានលើកផងដែរ ប្រសិនបើវាពាក់ព័ន្ធ។ ជាក់ស្តែង អសមត្ថភាពក្នុងការទទួលខុសត្រូវ ទំនងនឹងមិនពាក់ព័ន្ធទេ។ មានន័យថា អ្នកផលិត ជានីតិជន ដូចនេះ មិនអាចលើកថា មិនទទួលខុសត្រូវលើផលិតផលដែលមានវិការៈ ដោយសារគាត់គ្មានសមត្ថភាពក្នុងការទទួលខុសត្រូវទេ។

**ខ. ការទទួលខុសត្រូវលើផលិតផល**បាន លុះត្រាមានកំហុសចេតនា ឬអចេតនា ដូចជា មិនបានធ្វើតាមតាមស្តង់ដារតម្រូវ (duty to act) ដែលនាំឲ្យមានវិការៈ[11]។ ទោះបីមានវិការៈក្តី វាទាមទារឲ្យមានការខូចខាតដល់ភាគី ដើម្បីអាចទាមទារសំណងបាន លើកលែងតែករណី ដែលគ្រាន់តែមានវិការៈត្រូវបានគេចាត់ថាមានការខូចខាតហើយ។ ទោះបីជា វាជាទ្រឹស្តីទូទៅហើយថា អ្នកទាមទារ ត្រូវមានបន្ទុកបង្ហាញភស្តុតាង ហើយ ក្នុងករណីនេះ ជនរងគ្រោះត្រូវបង្ហាញថា ផលិតផល មានវិការៈ ហើយធ្វើឲ្យខូចខាត វានៅមិនទាន់មានភាពច្បាស់លាស់ថា តើជនរងគ្រោះ គ្រប់ប្រភេទនៃផលិតផល ទាំងអស់ត្រូវបង្ហាញវិការៈ។ វិការៈ មានវិការៈធម្មតា និងអាថ៌កំបាំង ដែលជនរងគ្រោះសាមញ្ញ មិនអាចមើលឃើញ ហើយទាមទារអ្នកជំនាញ ឬបច្ចេកវិជ្ជាទំនើបដើម្បីវាយតម្លៃវិការៈ។ នេះជារបា មួយសម្រាប់ ជនរងគ្រោះដាក់ពាក្យបណ្តឹង។ អាស្រ័យហេតុនេះ យុត្តាធិការខ្លះ តម្រូវឲ្យអ្នកផលិតបង្ហាញថា ផលិតផលខ្លួនគ្មានវិការៈ[12] ដើម្បីឆ្លើយតបនឹង ការសន្មតថាមានវិការៈ (presumed defect) ដោយសារ ផលិតករ ឬក្រុមហ៊ុន មានលទ្ធភាព និងសមត្ថភាពបញ្ជាក់។ មាត្រា ៧៤៣ ដាក់បន្ទុកភស្តុតាងដល់ជនរងគ្រោះ ស្របពេលនេះដែល ចែងអនុញ្ញាតនូវការលើកលែង ដែលមានក្នុងមាត្រាផ្សេងនៃក្រមនេះ ឬ ច្បាប់ផ្សេងៗទៀត។ ពាក់ព័ន្ធនឹងចំណុចនេះ មាត្រានៃក្រមរដ្ឋប្បវេណីបានចែង មាត្រា ៥៣៩៖១- *អ្នកលក់ត្រូវមានករណីយកិច្ចប្រគល់វត្ថុដែលគ្មានវិការៈឱ្យទៅអ្នកទិញ។* ចំណុចនេះ នៅមានមន្ទិល រំពឹងថា សាលក្រម ឬសាលដីកា តុលាការកម្ពុជា នឹងជួយបំភ្លឺ។

**គ.** ក្រមរដ្ឋប្បវេណី បានចែងក្នុងបទប្បញ្ញត្តិទូទៅ ឲ្យមានការសងសំណងសាមគ្គី[13] ដូចជាក្នុងករណី

---

[11] ក្រមរដ្ឋប្បវេណី មាត្រា ៧៤២។

[12] Coulter Boechen, Defenses in a Product Liability, p. 3, at. Defenses in a Product Liability Lawsuit | AllLaw (accessed on 17 December 2020).

[13] ក្រមរដ្ឋប្បវេណី មាត្រា ៧៥៤ (អ្នកត្រួតពិនិត្យ និងអនីតិជន)។

ដែលបុគ្គលពាក់ព័ន្ធក្នុងខ្សែសង្វាក់ផលិតកម្ម ផ្សំគំនិតគ្នា នាំឲ្យផលិតផលមានវិការៈ[14] ឬសងតាមសមាមាត្រាតាមចំណែកនៃកំហុស[15]។ ក្រោយពីជនណាមួយ សងសរុបហើយ គាត់អាចទាមទារឲ្យផលិតករដទៃយកតាមក្រោយនូវចំណែកតាមកំហុសមកឲ្យខ្លួន។[16] ស្រដៀងគ្នានេះដែរ និយោជិត នឹងសងថ្លៃទៅនិយោជក[17] មន្ត្រីរាជការសងទៅស្ថាប័នរបស់ខ្លួនវិញ[18]។ នេះ ក៏ត្រូវបានអនុវត្តផងដែរ ចំពោះការទទួលខុសត្រូវលើផលិតផល។ មាត្រា ៧៥១ និយាយប្រយោល អំពីបុគ្គល ដែលអាចត្រូវចាត់ថាជាផលិតករនៃផលិតផលសម្រេច ឬ គ្រឿងផ្សំ។ ពួកគេអាចមានចំណែកចូលរួមធ្វើឲ្យមានវិការៈ។

**ឃ.** ទោះបីមានវិការៈ និងបង្កខូចខាតដល់ជនរងគ្រោះ ជនរងគ្រោះ ត្រូវដាក់ពាក្យប្ដឹងទាមទារសំណងក្នុងរយៈពេលកំណត់ជាក់លាក់មួយ ប្រសិនបើមិនដូចនោះទេ ពាក្យបណ្ដឹងនឹងត្រូវបានបដិសេធហើយសំណងនឹងមិនត្រូវបានទទួលទេ។

*សិទ្ធិទាមទារសំណងនៃការខូចខាតដោយអំពើអនីត្យានុកូល ត្រូវរលត់សិទ្ធិដោយអាជ្ញាយុកាល បើអំឡុងពេល ៣ (បី) ឆ្នាំបានកន្លងហួសបន្ទាប់ពីពេលដែលជនរងគ្រោះ ឬអ្នកតំណាងដែលច្បាប់បានកំណត់របស់ជនរងគ្រោះនោះ បានដឹងថាអាចទាមទារសំណង ការខូចខាតចំពោះអ្នកប្រព្រឹត្តអំពើបំពាន ឬបើអំឡុងពេល ១០ (ដប់) ឆ្នាំបានកន្លងហួស បន្ទាប់ពីអំពើអនីត្យានុកូលនោះត្រូវបានប្រព្រឹត្តឡើង។*[19]

---

[14]Ministry of Justice, Note on Each Article of Civil Code, Book Five, 2010, ទំ. ១៩២។

[15] ក្រមរដ្ឋប្បវេណី មាត្រា ៧៥៤។

[16] ក្រមរដ្ឋប្បវេណី មាត្រា ៧៥៤។

[17] ក្រមរដ្ឋប្បវេណី មាត្រា ៧៤៧។

[18] ក្រមរដ្ឋប្បវេណី មាត្រា ៧៤៩។

[19] ក្រមរដ្ឋប្បវេណី មាត្រា ៧៥៦។

## តារាងបទញ្ញត្តិពាក់ព័ន្ធក្នុងក្រមរដ្ឋប្បវេណី

| ល | បទប្បញ្ញត្តិ |
|---|---|
| ១ | មាត្រា ៧៤៣.- លក្ខខណ្ឌ និងការទទួលខុសត្រូវក្នុងការបញ្ជាក់បង្ហាញនៃអំពើអនីត្យានុកូលទូទៅ<br>១- បុគ្គលដែលបំពានដោយខុសច្បាប់នូវសិទ្ធិ ឬផលប្រយោជន៍របស់ជនដទៃ ដោយកំហុសចេតនា ឬដោយកំហុសអចេតនា ត្រូវទទួលខុសត្រូវក្នុងការសងការខូចខាតដែលកើតឡើងដោយអំពើនោះ។<br>២- បញ្ញត្តិនៃកថាខណ្ឌទី១ខាងលើនេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះករណីដែលការខូចខាតបានកើតឡើងដោយសារ មានករណីយកិច្ចធ្វើអំពើណាមួយតែមិនបានធ្វើអំពើនោះ។<br>៣- ចំពោះកំហុសចេតនា ឬកំហុសអចេតនារបស់ចារីនេះ ទំនាក់ទំនងនៃហេតុផលរវាងអំពើរបស់អ្នកប្រព្រឹត្តអំពើបំពាន និងការកើតឡើងនៃការខូចខាត និងការខូចខាតដែលកើតមានឡើងលើជនរងគ្រោះ បុគ្គលដែលសិទ្ធិទាមទារសំណងការខូចខាតនោះ ត្រូវបញ្ជាក់បង្ហាញ លើកលែងតែបញ្ញត្តិពិសេសនៅក្នុងក្រមនេះ ឬច្បាប់ផ្សេងទៀត។ |
| ២ | មាត្រា ៧៤៩.- អំពើអនីត្យានុកូលរបស់មន្ត្រីរាជការ<br>១- បើមន្ត្រីរាជការដែលទទួលការអនុវត្តនូវអំណាចសាធារណៈរបស់រដ្ឋ ឬស្ថាប័នសាធារណៈ បានបង្កការខូចខាតដល់អ្នកដទៃដោយខុសច្បាប់ដោយកំហុសចេតនា ឬដោយកំហុសអចេតនា ក្នុងការអនុវត្តភារកិច្ចរបស់ខ្លួននោះ រដ្ឋ ឬស្ថាប័នសាធារណៈត្រូវទទួលខុសត្រូវក្នុងការសងការខូចខាតនោះ។<br>២- ក្នុងករណីដែលបានកំណត់នៅក្នុងកថាខណ្ឌទី១ខាងលើនេះ បើកម្រិតនៃការបំពានករណីយកិច្ចរបស់មន្ត្រីរាជការ ក្នុងការជៀសវាងនូវលទ្ធផលមានភាពធ្ងន់ធ្ងរ រដ្ឋ ឬស្ថាប័នសាធារណៈអាចទាមទារសំណងពីមន្ត្រីរាជការនោះបាន។ |
| ៣ | មាត្រា ៧៤៧.- ការទទួលខុសត្រូវរបស់និយោជក<br>១- បុគ្គលដែលប្រើនិយោជិតដើម្បីអនុវត្តកិច្ចការ ត្រូវទទួលខុសត្រូវក្នុងការសងការខូចខាត ដែលនិយោជិតបានបង្កដល់អ្នកដទៃដោយខុសច្បាប់ ដោយកំហុសចេតនា ឬកំហុសអចេតនានៅក្នុងការអនុវត្តកិច្ចការនោះ។ |

| | |
|---|---|
| | ២- បុគ្គលដែលស្ថិតនៅក្នុងឋានៈ ត្រូវត្រួតពិនិត្យនិយោជិតជំនួសនិយោជក ត្រូវទទួលខុសត្រូវដូចគ្នានឹងនិយោជកដែរ។ ប៉ុន្តែបញ្ញត្តិនេះមិនត្រូវយកមកអនុវត្តឡើយ ចំពោះករណីដែលបុគ្គលនោះបានត្រួតពិនិត្យដោយត្រឹមត្រូវ។<br>៣- និយោជក ឬអ្នកត្រួតពិនិត្យជំនួស អាចទាមទារសំណងពីនិយោជិតបានដោយយោងទៅតាមកម្រិតនៃកំហុសរបស់និយោជិតនោះ។ |
| ៤ | មាត្រា ៧៩៤.- អំពើអនីត្យានុកូលរួម<br>១- បើការខូចខាតបានកើតឡើង ដោយសារអំពើរបស់បុគ្គលច្រើននាក់រួមគ្នា អ្នកប្រព្រឹត្តអំពើបំពានទីមួយៗត្រូវទទួលខុសត្រូវក្នុងការសងការខូចខាតដោយសាមគ្គីភាព។<br>២- ក្នុងករណីដែលបានកំណត់នៅក្នុងកថាខណ្ឌទី១ខាងលើនេះ ប្រសិនបើអ្នកប្រព្រឹត្តអំពើបំពានទីមួយៗបានបញ្ជាក់អំពី ភាគនៃអំពើដែលខ្លួនបានបង្កឱ្យមានការខូចខាតជននោះត្រូវទទួលខុសត្រូវក្នុងការសងការខូចខាត តាមសមាមាត្រនៃភាគដែលខ្លួនបានបង្ក។ ប៉ុន្តែបញ្ញត្តិនេះមិនត្រូវយកមកអនុវត្តឡើយ ចំពោះករណីដែលទទួលស្គាល់ថាមានការសមគំនិត ឬមានទំនាក់ទំនងសហការយ៉ាងជិតស្និទ្ធក្នុងចំណោមអ្នកប្រព្រឹត្តអំពើបំពាន។<br>៣- បើជនម្នាក់ក្នុងចំណោមអ្នកប្រព្រឹត្តអំពើអនីត្យានុកូលរួម បានសងការខូចខាតទាំងអស់ ដោយចេញចំណាយរបស់ខ្លួន ជននោះអាចទាមទារសំណងពីអ្នកផ្សេងទៀតដែលប្រព្រឹត្តអំពើអនីត្យានុកូលរួមនោះបានតាមសមាមាត្រនៃភាគដែលជនម្នាក់ៗបានបង្ក។ |
| ៥ | មាត្រា ៧៩៦.- មូលហេតុរួចផុតពីភាពផ្ទុយច្បាប់<br>១- អ្នកប្រព្រឹត្តអំពើបំពានរួចផុតពីការទទួលខុសត្រូវ ក្នុងករណីដែលមានការយល់ព្រម ឬការទទួលយកគ្រោះថ្នាក់ពីសំណាក់អ្នករងគ្រោះ។ ប៉ុន្តែបញ្ញត្តិនេះមិនត្រូវយកមកអនុវត្តឡើយ ចំពោះករណីដែលការយល់ព្រម ឬការទទួលយកគ្រោះថ្នាក់នោះ មិនត្រូវបានសង្គមទទួលស្គាល់ថាសមហេតុផល។<br>២- ចំពោះការខូចខាតដែលកើតមានឡើងដោយសារអំពើការពារជាធម្មានុរូប ឬអំពើដោយសារស្ថានភាពចាំបាច់ អ្នកដែលបានប្រព្រឹត្តអំពើការពារ ឬអំពើដោយស្ថានភាពចាំបាច់ ពុំត្រូវទទួលខុសត្រូវឡើយ។ ក្នុងករណីនេះបុគ្គលដែលបានប្រព្រឹត្តអំពើផ្ទុយច្បាប់ ដែលជាមូលហេតុនៃអំពើនោះត្រូវទទួលខុសត្រូវ។<br>៣- ចំពោះការខូចខាតដោយសារអំពើដែលត្រូវសង្គមទទួលស្គាល់ថា សមហេតុផលអ្នកប្រព្រឹត្តអំពើបំពានមិនត្រូវទទួលខុសត្រូវឡើយ។ |